00866107

E218/7

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 12 / 2012
ម៉ោង (Time/Heure): 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អនុស្សរណៈ – អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ផ្ញើជូន:** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ផ្ញើពី:** និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០១ និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន៨០ *ស្ទួន*(៤))

តាមរយៈអនុស្សរណៈចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការណែនាំដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យកំណត់ និងរៀបចំសម្រាប់ការអនុវត្តសំណងជាអាទិភាពមួយចំនួនតូច ក្នុងចំណោមសំណងទាំងឡាយដែលស្ថិតក្រោមការពិចារណា ទាមទារនាពេលបច្ចុប្បន្ន ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន អនុលោមតាមវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង (ឯកសារ E218 កថាខណ្ឌ១៩)។ ការណែនាំដូច្នេះ គឺក្នុងន័យគោលបំណងធានាថាកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងការផ្តល់ជាសំណងអាចប្រព្រឹត្តិទៅប្រកបដោយអត្ថន័យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយមួយវិញទៀតដោយសារតែមូលនិធិម្ចាស់ជំនួយ ព្រមទាំងធនធានមនុស្សមានកំណត់ទាំងនៅផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងនៅអង្គភាពគាំពារជនរងគ្រោះ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញថា ខ្លួនបានចងក្រងគម្រោងមួយចំនួនតូចចេញពីក្នុងចំណោមគម្រោងសំណង សរុប

ទាំងអស់ដែលបានកំណត់ អនុលោមតាមវិធាន៨០ *ស្ទួន (៤)* នៃវិធានផ្ទៃក្នុង ហើយនឹងគូសបញ្ជាក់គម្រោងអាទិភាពទាំងនោះ និងជូនដល់អង្គជំនុំជម្រះក្នុងពេលសមស្រប ( ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១២ ទំព័រ៧-៨)។

អនុលោមតាមវិធាន ៨០ ស្ទួន (៤) នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខត្រូវបានស្នើសុំឱ្យបញ្ជាក់នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៣ អំពីបញ្ជីគម្រោងសំណងជាអាទិភាពដែលបច្ចុប្បន្នកំពុងត្រូវបានរៀបចំដើម្បីដាក់ជូនមកអង្គជំនុំជម្រះ។ ដោយពិចារណាទៅលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តសំណង ដូចដែលបានលើកឡើងដោយសហមេធាវីនាំមុខអន្តរជាតិក្នុងកិច្ចប្រជុំរៀបចំសវនាការថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា ការអនុវត្តវិធានការទាំងនេះអាចនឹងចាប់ផ្តើមមុនការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១។ គោលបំណងនេះគឺស្របទៅនឹងការអនុម័តវិធាន ២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង ដែលនឹងជម្រុញដល់ការអនុវត្តសំណងប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្រប ដោយមានជំនួយពីមូលនិធិម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ។ បន្ថែមលើនេះទៀត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះត្រូវបានស្នើឱ្យកំណត់អំពីមូលដ្ឋាននៃមូលនិធិអាទិភាពឱ្យបានឆាប់ ដើម្បីគាំទ្រគម្រោងទាំងនោះ ដែលនឹងត្រូវស្នើសុំជាសំណង។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណទុកជាមុន ប្រសិនបើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការប្រឹក្សាយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ អាចផ្តល់ព័ត៌មានអំពីស្ថានភាពបច្ចុប្បន្ននៃការផ្តល់ហិរញ្ញវត្ថុដល់គម្រោងអាទិភាពរបស់ពួកគេ។ នៅពេលទទួលបានព័ត៌មានទាំងនេះហើយ ឬនៅពេលក្រោយមកទៀត អង្គជំនុំជម្រះអាចនឹងស្នើសុំការបញ្ជាក់បន្ថែមទៀត។